ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

សេចក្តីប្រកាសព័ត៌មាន

## «កម្ពុជា និង ជប៉ុន នឹងបង្កើនកិច្ចសហប្រតិបត្តិការលើ វិស័យរក្សាសន្តិភាព និងសកម្មភាពកំចាត់មីន»

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០២៣ - «កម្ពុជា បង្ហាញពីគំរូដ៏ល្អនៅក្នុងវិស័យសន្តិភាព និងសន្តិសុខអន្តរជាតិ ហើយត្រូវបានទទួលស្គាល់ថា ជាអ្នកផ្តល់សន្តិភាព» នេះគឺជាការកោតសរសើររបស់ **ឯកឧត្តម កាណូ តាគេហ៊ីរ៉ូ** (KANO Takehiro) អគ្គនាយកនៃទីស្នាក់ការកិច្ចសហប្រតិបត្តិការសន្តិភាពអន្តរជាតិ នៃគណៈរដ្ឋមន្ត្រីជប៉ុន ក្នុងឱកាសដែល ឯកឧត្តម បានចូលជួបសម្តែងការគួរសម ជាមួយ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០២៣ នាទីស្តីការក្រសួង។

ភាគីទាំងពីរ បានសម្តែងនូវការពេញចិត្តចំពោះទំនាក់ទំនងទ្វេភាគីដ៏រឹងមាំ ដែលត្រូវបានតម្លើងដល់កម្រិត "ដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ" នៅក្នុងឆ្នាំនេះ។ ភាគីទាំងពីរ ក៏បានពិភាក្សាគ្នាផងដែរអំពីភាពជាដៃគូក្នុងកិច្ចការរក្សាសន្តិភាព និងសកម្មភាពកំចាត់មីន នៅក្នុងក្របខ័ណ្ឌទ្វេភាគី ត្រីភាគី និងអង្គការសហប្រជាជាតិ។ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានរំលឹកឡើងវិញជាមួយសេចក្តីអំណរគុណ ចំពោះការរួមចំណែកដ៏សំខាន់របស់កងកម្លាំងស្វ័យការពារជប៉ុន នៅក្នុងដំណើរការរក្សាសន្តិភាព ក៏ដូចជា ការគាំទ្ររបស់ជប៉ុនជាបន្តបន្ទាប់ សម្រាប់ការកសាងឡើងវិញ និងការអភិវឌ្ឍគ្រប់ជ្រុងជ្រោយរបស់កម្ពុជា។

ឯកឧត្តមអគ្គនាយក បានបញ្ជាក់ពីការត្រៀមខ្លួនរបស់ជប៉ុន ធ្វើការជាមួយកម្ពុជា ដែលនឹងធ្វើជាប្រទេសម្ចាស់ផ្ទះរៀបចំ "កម្មវិធីភាពជាដៃគូត្រីភាគីរបស់អង្គការសហប្រជាជាតិ" នៅឆ្នាំ២០២៤ ដើម្បីពង្រឹងសមត្ថភាពវិស្វកម្មក្នុងតំបន់ នៅក្នុងបេសកកម្មរក្សាសន្តិភាព។ ភាគីទាំងពីរ បានគូសបញ្ជាក់ជាថ្មី អំពីការប្តេជ្ញាចិត្ត ក្នុងការពង្រីកកិច្ចសហការបន្ថែមទៀត នៅក្នុងវិស័យសន្តិភាព និងសន្តិសុខអន្តរជាតិ តាមរយៈការបណ្តុះបណ្តាល និងការផ្តល់គ្រឿងបរិក្ខារ។

ភាគីទាំងពីរ ក៏បានផ្លាស់ប្តូរទស្សនៈលើបញ្ហាតំបន់មួយចំនួនផងដែរ។ ឯកឧត្តមអគ្គនាយក បានសាទរចំពោះជោគជ័យរបស់កម្ពុជា ក្នុងនាមជាប្រធានអាស៊ាន និងតួនាទីដ៏លំបាករបស់ប្រេសិតពិសេសរបស់ប្រធានអាស៊ាន ស្តីពីមីយ៉ាន់ម៉ា កាលពីឆ្នាំមុន និងបានសង្កត់ធ្ងន់ថា កិច្ចខិតខំប្រឹងប្រែងដ៏ធំធេងរបស់កម្ពុជា ត្រូវបានទទួលស្គាល់យ៉ាងច្បាស់ ដោយប្រទេសជប៉ុន និងសហគមន៍អន្តរជាតិ៕